W1.2.42(F)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខៈ ០៤៦ ក.ទ.ច
ពស.ក.រប

មិនគិតកម្រៃអាជ្ញាប័ណ្ណ
ឆ្នាំ២០២១

CAMBODIA
Kingdom of Wonder
feel the warmth

# អាជ្ញាប័ណ្ណទេសចរណ៍
# TOURISM LICENSE



អនុញ្ញាតឱ្យលោក~លោកស្រី តាន់ សនជូន TAN SEAN CZOON (ម៉ាឡេស៊ី)

ស្ថិតនៅផ្ទះលេខ អគារណាហ្គាវើលដ៍ ផ្លូវ សួនសម្តេចតេជោហ៊ុនសែន សង្កាត់ ទន្លេបាសាក់

ក្រុង~ស្រុក~ខណ្ឌ ចំការមន រាជធានី~ខេត្ត ភ្នំពេញ

ប្រកបអាជីវកម្ម សណ្ឋាគារ (បន្ត) (ចំណាត់ថ្នាក់ផ្កាយ ៥)

អាជីវកម្មឈ្មោះ ណាហ្គាវើលដ៍ NAGAWORLD HOTEL

ចាប់ពីថ្ងៃទី ១៣ - ០១ - ២០២១ (13-01-21) ដល់ ១២ - ០១ - ២០២២ (12-01-22)

ថ្ងៃ ពុធ ១១ កើត ខែ បុស្ស ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២១

រដ្ឋមន្ត្រី

ថោង ខុន

MINISTRY OF TOURISM

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១២១ សរ.ទក

ថ្ងៃ ច័ន្ទ ១១កើត ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០២១

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

### សូមបញ្ជាក់

សណ្ឋាគារ មួយត្រូវបានអនុញ្ញាតឲ្យបន្តអាជីវកម្មពេញលក្ខណៈច្បាប់តាមលក្ខខណ្ឌដូចខាងក្រោម៖

| | |
|---|---|
| ១- នាមករណ៍របស់សណ្ឋាគារ | : **ណាហ្គាវើលដ៍** NAGAWORLD HOTEL |
| ២- អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : ០០០១៥៤០១ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២ |
| មានសុពលភាពពីថ្ងៃ | : ១៣ - ០១ - ២០២១ ដល់ ១២ - ០១ - ២០២២ |
| ឆ្នាំបង្កើត | : ២០០៨ |
| ៣- ឈ្មោះម្ចាស់ សណ្ឋាគារ | : លោក **តាន់ សេនជូន** TAN SEAN CZOON Mr. (ម៉ាឡេស៊ី) |
| ៤- អាសយដ្ឋាន សណ្ឋាគារ | : អគារណាហ្គាវើលដ៍ ផ្លូវ សួនសម្តេចតេជោហ៊ុនសែន សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ |
| ទូរស័ព្ទ - ទូរសារ - សារអេឡិកត្រូនិក | : ០២៣ ២២៨ ៨២២ / ០២៣ ២២៥ ៨៨៨ |
| ៥- ប្រភេទអាជីវកម្ម | : សណ្ឋាគារមាន **១៦៥៨** បន្ទប់ Single: 924 Twin: 644 Suite: 90 |
| ៦- ចំនួនបុគ្គលិក | : មាន ៤៧៦៣នាក់ (ប្រុស:៣១០៥នាក់ ស្រី:១៦៥៨នាក់ ក្នុងនោះបរទេស: ២៣៨) |

ក្នុងពេលដំណើរការបន្តអាជីវកម្ម សណ្ឋាគារ ត្រូវគោរពតាមបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ ច្បាប់ស្តីពីទេសចរណ៍ និងច្បាប់ផ្សេងៗរបស់រដ្ឋ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

**សុខ សុខហាប់**

ចម្លងជូន៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- សាលារាជធានីភ្នំពេញ " ដើម្បីជូនជ្រាប "
- មន្ទីរទេសចរណ៍រាជធានីភ្នំពេញ " ដើម្បីមុខការ "
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១២១ ទសណរប

ថ្ងៃ ច័ន្ទ ១១ កើត ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០២១

## ជម្រាបមក

## លោក តាន់ សនជូន ម្ចាស់សណ្ឋាគារ ណាហ្គាវើលដ៍
## NAGAWORLD HOTEL

**កម្មវត្ថុ ៖** ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្ម សណ្ឋាគារ (បន្ត) ។

**យោង ៖** - ព្រះរាជក្រមលេខ នស / រកម / ០៦០៩ / ០០៧ ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍

- ប្រកាសលេខ ០៦៣ ប្រក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់សណ្ឋាគារ និង សេវាកម្មស្នាក់នៅទេសចរណ៍
- សារាចរណែនាំលេខ ០០៣ សរណន ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រង អាជីវកម្មសណ្ឋាគារ និង សេវាកម្មស្នាក់ទេសចរណ៍
- អាជ្ញាបណ្ណទេសចរណ៍លេខ ០៩០/២០ក.ទ.ច.អប.សគចុះថ្ងៃទី១៧ខែកុម្ភៈឆ្នាំ២០២០ របស់ក្រសួងទេសចរណ៍
- កិច្ចសន្យារបស់ម្ចាស់សណ្ឋាគារ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២០
- សំណើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្ម សណ្ឋាគារ របស់លោក **តាន់ សនជូន** ម្ចាស់សណ្ឋាគារ **ណាហ្គាវើលដ៍** ដែលមានចំនួន **១៦៥៨** បន្ទប់ ស្ថិតនៅអគារណាហ្គាវើលដ៍ ផ្លូវ សួនសម្តេចតេជោ ហ៊ុន សែន សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ
- យោងចំណារឯកភាពរបស់ឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី 11 ខែ កុម្ភៈ ឆ្នាំ 2021 ។

ក្រសួងទេសចរណ៍ឯកភាពជាគោលការណ៍ ផ្តល់អាជ្ញាបណ្ណទេសចរណ៍ សណ្ឋាគារ ជូនដល់ម្ចាស់សណ្ឋាគារ **ណាហ្គាវើលដ៍** បន្តអាជីវកម្មរបស់ខ្លួនចាប់ពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២១ ដល់ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២២។

ម្ចាស់ សណ្ឋាគារ ត្រូវគោរពគោលការណ៍ លក្ខខណ្ឌ ដូចខាងក្រោម ៖

១- គោលការណ៍ លក្ខខណ្ឌណែនាំ និងច្បាប់ទាំងឡាយ ដែលត្រូវបានកំណត់ក្នុងលិខិតបទដ្ឋានខាងលើ

២- ហាមដាច់ខាត ដាក់លក់ ឬ ប្រើប្រាស់គ្រឿងញៀន និង ជួញដូរផ្លូវភេទគ្រប់រូបភាព។

៣- ត្រូវធានាមិនឱ្យមានការប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ សុវត្ថិភាព និង ទំនៀមទំលាប់ ប្រពៃណីជាតិ។

៤- ក្នុងដំណើរការប្រកបអាជីវកម្មរបស់ខ្លួន ត្រូវអនុវត្តតាមច្បាប់ជាធរមាន របស់រដ្ឋតាមការណែនាំ និងលិខិត បទប្បញ្ញត្តិរបស់ក្រសួង និង មិនធ្វើអាជីវកម្មផ្សេងៗទៀតដោយគ្មានការអនុញ្ញាត ។

៥- ក្នុងករណីដំណើរការអាជីវកម្ម បើមានការផ្ទេរឈ្មោះម្ចាស់ ឬ អ្នកគ្រប់គ្រង ប្តូរឃីហោឈ្មោះទៅឱ្យអ្នកផ្សេង ម្ចាស់សណ្ឋាគារ ត្រូវជូនដំណឹងមកក្រសួងទេសចរណ៍ ឬ មន្ទីរទេសចរណ៍ឱ្យបានមុនយ៉ាង

តិចពីរសប្តាហ៍។

៦- សហការណ៍ និងរាយការណ៍ ជូនអាជ្ញាធរមានសមត្ថកិច្ច នូវបាតុភូតអសកម្មដែលបណ្តាលឲ្យប៉ះពាល់ សន្តិសុខ សុវត្ថិភាពភ្ញៀវ និង បុគ្គលិករបស់ សណ្ឋាគារ ឲ្យបាន២៤ ម៉ោង លើ ២៤ ម៉ោង។

៧- ម្ចាស់ សណ្ឋាគារ ត្រូវអនុវត្តឲ្យបាននូវការចុះបញ្ជីស្នាក់នៅរបស់ភ្ញៀវ។

៨- ធានាថែទាំ សំអាតនូវរាល់គ្រប់ផ្នែកទាំងអស់របស់សណ្ឋាគារ ឲ្យបានល្អ និងមានអនាម័យខ្ពស់បំផុត។

៩- លក្ខណៈនៃការតុបតែងលំអ និង ការបំពាក់សំភារៈបរិក្ខារ ត្រូវរក្សាឲ្យបាននូវ ទំនៀមទំលាប់ ប្រពៃណី និងវប្បធម៌ជាតិ ។

១០-ហាមទទួលភ្ញៀវអាយុក្រោម ១៦ ឆ្នាំ លើកលែងការស្នាក់នៅជាលក្ខណៈគ្រួសារ។

១១- ចូលរួមយុទ្ធនាការទេសចរម្នាក់ដាំដើមឈើ១ដើម ដើម្បីគាំទ្រ និងចូលរួមកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកំដៅផែនដី ។

១២-ចូលរួមផ្សព្វផ្សាយដល់បុគ្គលិក និងទេសចរក្នុងការការពារថែរក្សា អនាម័យ បរិស្ថាន និងបង្កើតការយល់ដឹងអំពីវិធានការកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី ទឹក និងការគ្រប់គ្រងកាកសំណល់។

១៣-គាំទ្រ និងចូលរួមយុទ្ធនាការឃោសនាផ្សព្វផ្សាយ **"កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ"** និងចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ"** និងជំរុញចលនាទេសចរក្នុងស្រុកឲ្យមានកំណើនខ្ពស់ ។

១៤- មិនត្រូវតម្លើងថ្លៃបន្ទប់នៅពេលមាន បុណ្យជាតិ អន្តរជាតិ និងព្រឹត្តិការណ៍ផ្សេងៗ ។

១៥-ត្រូវដាក់ព្យួរអាជ្ញាបណ្ណទេសចរណ៍ នៅកន្លែងដែលងាយស្រួលមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្ម "ងាយស្រួលដល់សមត្ថកិច្ចគ្រប់ស្ថាប័នចុះត្រួតពិនិត្យ" ។

១៦-ត្រូវគោរពតាម សេចក្តីណែនាំរបស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៦ ស្តីពី បរិស្ថានគ្មានផ្សែងបារីដល់អ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្ម សណ្ឋាគារ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

១៧-ត្រូវគោរពសារាចរណែនាំរបស់ក្រសួងទេសចរណ៍លេខ ០០១ សរណន ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីការពង្រឹងសន្តិសុខ សុវត្ថិភាពនៅតាមបណ្តាមូលដ្ឋានអាជីវកម្មស្នាក់នៅទេសចរណ៍។

ករណីមិនប្រតិបត្តិតាមគោលការណ៍ លក្ខខណ្ឌខាងលើ ក្រសួងនឹងមានវិធានការសមស្របតាមបទប្បញ្ញត្តិ របស់ក្រសួងទេសចរណ៍ ច្បាប់ស្តីពីទេសចរណ៍ និងច្បាប់ផ្សេងៗរបស់រដ្ឋជាធរមាន។

អាស្រ័យដូចបានជម្រាបជូន និង ណែនាំខាងលើ សូមលោក អនុវត្តតាមគោលការណ៍ឲ្យបានត្រឹមត្រូវ និងហ្មត់ចត់ជាទីបំផុត។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**សុខ គុងហាប់**

<u>ចម្លងជូនៈ</u>

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  (នាយកដ្ឋានពន្ធដារ)
- សាលារាជធានីភ្នំពេញ
  (ដើម្បីជ្រាបជាព័ត៌មាន)
- ឯកសារ.កាលប្បវត្តិ